# កម្មវិធីឃ្លាំមើលសវនាការសាលាក្ដីខ្មែរក្រហម




**Asian International Justice Initiative (AIJI), a project of East-West Center and the WSD Handa Center for Human Rights and International Justice at Stanford University (previously known as the UC Berkeley War Crimes Studies Center)**

# របាយការណ៍ប្រចាំសប្តាហ៍ លេខ៣

នាសប្តាហ៍នេះ អង្គជំនុំជម្រះតុលាការកំពូល បានផ្តើមការប្រជុំជាលើកដំបូងក្នុងឆ្នាំ២០១៦ ដើម្បីគ្រប់គ្រងសវនាការលើបណ្តឹងសាទុក្ខលើកទី២ របស់ភាគីប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង០០២ វគ្គ១ ដែលបានប្រកាសកាលពីថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤។[1] ក្នុងសាលក្រមរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ជនជាប់ចោទលោក **នួន ជា** និងលោក **ខៀវ សំផន** មានពិរុទ្ធភាពនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មានដូចជា៖ ការធ្វើមនុស្សឃាត អំពើអមនុស្សធម៌ ការជម្លៀសដោយបង្ខំ ការបង្ខំឲ្យបាត់ខ្លួន និងការប្រឆាំងនឹងសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ ក្នុងទឹកដីនៃព្រះជាណាចក្រកម្ពុជា នៅចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងចុងឆ្នាំ១៩៧៧។ ជនជាប់ចោទទាំងពីររូប ត្រូវបានកាត់ទោសឲ្យជាប់គុកអស់មួយជីវិត។ ក្រុមមេធាវីការពារក្តីនីមួយៗ បានកំពុងប្តឹងជំទាស់នឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដោយបានលើកឡើងអំពីទឡ្ហីករណ៍ចំនួន ៣៧០ ដោយបង្ហាញពីកំហុសមួយចំនួនទាំងក្នុងអង្គហេតុ និងអង្គច្បាប់។[2] ការិយាល័យសហព្រះរាជអាជ្ញា ក៏

[1] "សាលក្រមលើសំណុំរឿង០០២ វគ្គ១" របស់អង្គជំនុំជម្រះសាលាដំបូង (ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤) លេខ E313. [តទៅនេះហៅថា **សាលក្រម**]។

[2] ក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទលោក **នួន ជា** បានដាក់សារណាដោយមានទឡ្ហីករណ៍ចំនួន ២២៣ សម្រាប់ប្តឹងសាទុក្ខ *សូមមើល* ក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទលោក **នួន ជា** ស្តីពី "បណ្តឹងសាទុក្ខរបស់ **នួន ជា** ប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង០០២ វគ្គ១" (ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤) លេខ F16 [តទៅនេះហៅថា **បណ្តឹងសាទុក្ខរបស់ នួន ជា**] ។ រីឯក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទលោក **ខៀវ សំផន** បានដាក់សារណាដោយមានទឡ្ហីករណ៍ចំនួន ១៤៨ សម្រាប់ប្តឹងសាទុក្ខ *សូមមើល* ក្រុមមេធាវីការពារក្តីឲ្យជនជាប់

បានកំពុងធ្វើការប្តឹងសាទុក្ខលើសាលក្រមនេះផងដែរ ដោយបានសម្អាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ដោយមិនបានប្រើប្រាស់ទ្រឹស្តីសហឧក្រិដ្ឋកម្មទម្រង់ទូលាយទូទៅ នៅពេលធ្វើការវាយតម្លៃលើពិរុទ្ធភាពរបស់ជនជាប់ចោទ។[3]

សវនាការលើបណ្តឹងសាទុក្ខលើកទីមួយ ត្រូវបានធ្វើឡើងកាលពីខែកក្កដា ឆ្នាំ២០១៥។[4] សវនាការលើបណ្តឹងសាទុក្ខក្នុងសប្តាហ៍នេះ ដើមឡើយ ត្រូវបានគ្រោងកាលវិភាគរៀបចំឡើងនៅខែវិច្ឆិកា ឆ្នាំ២០១៥ ក៏ប៉ុន្តែសវនាការកាលនោះត្រូវបានពន្យារពេល ក្រោយពេលដែលក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទលោក **នួន ជា** បានធ្វើពហិការកិច្ចដំណើរការនីតិវិធីសវនាការ។[5] មេធាវីជាតិទាំងពីរការពារក្តីឲ្យជនជាប់ចោទលោក **នួន ជា** បានមានវត្តមានក្នុងបន្ទប់សវនាការនាសប្តាហ៍នេះ ដែលប្រការនេះបានធ្វើឲ្យកិច្ចដំណើរការនីតិវិធីសវនាការ អាចប្រព្រឹត្តទៅបាន ទោះបីជាយ៉ាងនេះក្តី មេធាវីការពារក្តីឲ្យលោក **នួន ជា** បានរក្សាជំហរដែលពួកគេបានប្រកាសក្នុងសវនាការកាលពីខែវិច្ឆិកាកន្លងទៅថា ពួកគេនឹង "មិនចូលរួមកិច្ចដំណើរការនីតិវិធីសវនាការទាំងនោះតទៅទៀតឡើយ ហើយក៏មិន...ធ្វើការឆ្លើយតបទៅរាល់សំណួរទាំងអស់ផងដែរ"[6] រីឯមេធាវីអន្តរជាតិការពារក្តីឲ្យជនជាប់ចោទលោក **នួន ជា** ក៏មានវត្តមានពេញមួយសប្តាហ៍នេះ។ ទឡ្ហីករណ៍រាប់រយនៃការប្តឹងសាទុក្ខដែលត្រូវបានសរសេរជាលាយលក្ខណ៍អក្សរនេះ ត្រូវបានកំណត់ជាក្រុមៗ ដោយបានបែងចែកជាប្រាំមួយវគ្គប្រធានសម្រាប់ការធ្វើទឡ្ហីករណ៍ផ្ទាល់មាត់ និងត្រូវបានប្រើប្រាស់រយៈពេលចំនួនបីថ្ងៃនៃកិច្ចដំណើរការនីតិវិធីសវនាការ។ ភាគីទាំងអស់ ត្រូវបានផ្តល់ពេលវេលាដើម្បីធ្វើការឆ្លើយតបទៅនឹងទឡ្ហីករណ៍នានាដែលធ្វើដោយភាគីម្ខាងទៀត។[7] នៅទីបញ្ចប់នៃកិច្ចដំណើរការនីតិវិធីសវនាការ ជនជាប់ចោទលោក **ខៀវ សំផន** បានធ្វើសេចក្តីថ្លែងការណ៍ ដោយបានបដិសេធនឹងបទចោទនានា ហើយបានបញ្ជាក់ថា គាត់ "មិនដែលចង់យល់ព្រមឲ្យមានគោលនយោបាយណាមួយ ដែលប្រឆាំងនឹងប្រជាជនកម្ពុជាខ្លួនឯងនោះឡើយ"។ រីឯជនជាប់ចោទលោក **នួន ជា** បានរក្សាជំហរ

---

ចោទលោក **ខៀវ សំផន** ស្តីពី "បណ្តឹងសាទុក្ខរបស់ **ខៀវ សំផន** ប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង០០២ វគ្គ១" (ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤) លេខ F17 [តទៅនេះហៅថា **បណ្តឹងសាទុក្ខរបស់ ខៀវ សំផន** ]។

[3] ការិយាល័យសហព្រះរាជអាជ្ញា ស្តីពី "បណ្តឹងសាទុក្ខរបស់ **សហព្រះរាជអាជ្ញា** ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០២ វគ្គ១" (ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៤) លេខ F11 [តទៅនេះហៅថា **បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា**]។

[4] របាយការណ៍របស់អ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហមក្នុងបណ្តឹងសាទុក្ខលើសំណុំរឿង០០២ វគ្គ១ លេខ១ ស្តីអំពីសវនាការលើបណ្តឹងសាទុក្ខលើកទី១ (ចុះថ្ងៃទី២ ដល់ទី៦ ខែកក្កដា ឆ្នាំ២០១៥) [តទៅនេះហៅថា **របាយការណ៍បណ្តឹងសាទុក្ខលេខ១**]។

[5] របាយការណ៍របស់អ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហមក្នុងបណ្តឹងសាទុក្ខលើសំណុំរឿង០០២ វគ្គ១ លេខ២ ស្តីអំពីសវនាការលើបណ្តឹងសាទុក្ខលើកទី២ (ចុះថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១៥)។

[6] ជនជាប់ចោទលោក **នួន ជា** បានរៀបរាប់ចំណុចសំខាន់ៗដោយខ្លួនគាត់ផ្ទាល់ ស្តីពីជំហររបស់គាត់ក្នុងសេចក្តីថ្លែងការណ៍មួយដែលគាត់បានធ្វើនៅក្នុងសវនាការលើបណ្តឹងសាទុក្ខកាលពីខែវិច្ឆិកា *សូមមើល* អង្គជំនុំជម្រះតុលាការកំពូល ស្តីពី "ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីសវនាការបណ្តឹងសាទុក្ខ" (ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៥) លេខ F1/4.1 បន្ទាត់លេខ ២៣ដល់លេខ២៥ [តទៅនេះហៅថា **ប្រតិចារឹកបណ្តឹងសាទុក្ខខែវិច្ឆិកា**]។

[7] អង្គជំនុំជម្រះតុលាការកំពូល ស្តីពី "ដីកាកំណត់កាលបរិច្ឆេទសវនាការលើបណ្តឹងសាទុក្ខ" (ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៥) លេខ F30/17 ក៏រួមបញ្ចូលឧបសម្ព័ន្ធ ក ស្តីពី "កាលវិភាគស្ថាពរសម្រាប់សវនាការ" (ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥) លេខ F30/17.1 ។

របស់គាត់ក្នុងការប្រើប្រាស់សិទ្ធិនៅស្ងៀម។ អង្គជំនុំជម្រះតុលាការកំពូល ត្រូវបានរំពឹងទុកថានឹងធ្វើសេចក្តីសម្រេចស្ថាពរលើការប្តឹងសាទុក្ខនេះ នៅពាក់កណ្តាលឆ្នាំ២០១៦ នាពេលខាងមុខ។[8]

---

* របាយការណ៍នេះ ត្រូវបានសរសេរដោយ ជា បូរក្សមុនី, ម៉ាលេនី ហៃដ៍ (Melanie Hyde), ខេតលីន កាហ្វ្រៀ (Caitlin McCaffrie), អេលេហ្សាប៊ែត អ័រ (Elizabeth Orr), ធី ស៊ុន (Thi Son), តាយ លីណា និង ភីនីឡូភី វ៉ាន់ ធូល (Penelope Van Tuyl) ដែលជាផ្នែកមួយនៃកម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម និងការផ្សព្វផ្សាយតាមសហគមន៍របស់អង្គការគម្រោងផ្តួចផ្តើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី(AIJI)។ AIJI គឺជាគម្រោងកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលបស្ចិម-បូព៌ា (East-West Center) នៅអូណូឡូឡូ (Honolulu) និងមជ្ឈមណ្ឌល ដាប់ប៊ែលយូ.អេស.ឌី ហាន់ដា សម្រាប់សិទ្ធិមនុស្ស និងយុត្តិធម៌អន្តរជាតិ (WSD Handa Center) ដែលកាលពីមុនត្រូវបានគេស្គាល់ថាជា មជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាម ប៊ែកឃ្លី (Berkeley War Crime Study Center)។ ចាប់តាំងពីឆ្នាំ២០០៣មក មជ្ឈមណ្ឌលទាំងពីរនេះ បានកំពុងធ្វើកិច្ចសហប្រតិបត្តិការគ្នាលើគម្រោងជាច្រើន ដែលពាក់ព័ន្ធនឹងការបង្កើតការផ្តួចផ្តើមយុត្តិធម៌ និងកម្មវិធីកសាងសមត្ថភាពនានាក្នុងវិស័យសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីអាគ្នេយ៍នេះ។

EAST-WEST CENTER

AIJI TRIAL MONITORING

WSD HANDA CENTER FOR HUMAN RIGHTS & INTERNATIONAL JUSTICE
Stanford University

---

[8] ការកែសម្រួលលើកទី៧ នៃគម្រោងផែនការបិទបញ្ចប់ **អ.វ.ត.ក** ធ្វើនៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦។